# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ០១.ប្រក-២០០០

# ប្រកាសរួម

## ស្តីពី

### ការកំណត់ប្រាក់ឧបត្ថម្ភ សម្រាប់សវនាការ ជំនុំជម្រះក្តីរបស់តុលាការ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ១១៩៨/ ៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជាដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ០៦ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/ រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-តាមសំណើរបស់តុលាការ

ភារកិច្ចទទួលយកកុមារយុវកុមារខិលខូចដែលបញ្ជូនដោយនគរបាល អាចប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលសិទ្ធិសេរីភាពមាតាបិតានៃកុមារចែងក្នុងរដ្ឋធម្មនុញ្ញ ចំណែកខាងច្បាប់គ្រួសាររបស់រដ្ឋកម្ពុជា ឆ្នាំ១៩៨៩ ដែលនៅជាធរមានដោយមាត្រា ១៥៨ ថ្មី នៃរដ្ឋធម្មនុញ្ញក៏ទទួលស្គាល់តែឳពុកម្តាយរបស់កុមារនោះប៉ុណ្ណោះ ដែលមានសិទ្ធិគ្រប់គ្រង បីបាច់ថែរក្សាជាអាណាព្យាបាល ហើយមានតែច្បាប់ទេទើបអាចដកហូតសិទ្ធិសេរីភាពនេះបាន ។

ដូច្នេះហើយបានជាតុលាការដែលទទួលអំណាចដោយច្បាប់នីតិវិធីអាចដកហូតផ្ទេរសិទ្ធិ ឬបណ្តោះអាសន្ន ឬ អចិន្ត្រៃយ៍ទៅឱ្យ ឬអង្គការដូចក្រសួងយុវនីតិសម្បទា ឬឯកជនដើម្បីប្រើសិទ្ធិ ឬអំណាចជំនួសសិទ្ធិ និងអំណាចមេបានេះបាន ។

ការផ្ទេរសិទ្ធិ ឬផ្ទេរអំណាចមេបាដោយគ្មានសាលក្រម ជាការរំលោភច្បាប់ លើកលែងតែការផ្ទេរអំណាចអាណាព្យាបាល លើកុមារអាណាថាដែលគ្មានអាណាព្យាបាល ទើបអាចធ្វើបានដោយមានឬមិនបាច់មានសាលក្រម ប៉ុន្តែជាគោលការណ៍ត្រូវមានសាលក្រមទើបមានការធានាជាង ។

ដូច្នេះខ្ញុំសូមឯកឧត្តម មេត្តាពិនិត្យលទ្ធភាពទទួលយកតែក្មេងដែលមានសាលក្រមរបស់តុលាការ ប្រគល់ជូនតែប៉ុណ្ណោះដើម្បីជៀសវាងការឃុំឃាំងបុគ្គលខុសច្បាប់ ដូចជាករណីកុមារ គង់ រតនា ជាដើម ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០

**អគ្គព្រះរាជអាជ្ញា**

**ហង់រ៉ូ វ៉ាកេន**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ចៅក្រម, ព្រះរាជអាជ្ញា ខេត្ត-ក្រុង

-ដើម្បីជូនជ្រាបនិងជ្រាប